# ព្រះរាជាណាចក្រកម្ពុជា
# ជាតិ សាសនា ព្រះមហាក្សត្រ

++++++++++++

## កិច្ចព្រមព្រៀងព្យួរកិច្ចសន្យាការងារ

កិច្ចព្រមព្រៀងព្យួរកិច្ចសន្យាការងារនេះ ត្រូវបានធ្វើឡើងនៅថ្ងៃទី ២២ មិនា ២០២១ រវាង

**លោកស្រី ជឹម សុខនី** កាន់អត្តសញ្ញាណប័ណ្ណសញ្ញាតិខ្មែរលេខ ០១១០៧០១៩៣ ដែលមានតួនាទីជា **ប្រធានគ្រប់គ្រង រោងនីដ្ឋាន** និងជាតំណាងភាគីនិយោជក នៃក្រុមហ៊ុន **វើលដ៍ ដាយនីង លីមីធីត** ដែលមានអាសយដ្ឋានស្ថិតនៅ ផ្ទះ ២៨ ផ្លូវសម្តេចសុធារស សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ

និង

**លោក ឡឿន ចក្រវ៉ា** កាន់អត្តសញ្ញាណប័ណ្ណសញ្ញាតិខ្មែរលេខ ០១០៦៦១៨៣២ ដែលមានតួនាទីជា

**ប្រធានផ្នែក ចុងភៅ** និងជាតំណាងភាគីនិយោជិក នៃក្រុមហ៊ុនខាងលើ។

ភាគីទាំងពីរបានធ្វើការព្រមព្រៀងគ្នាដូចខាងក្រោម៖

**មាត្រា១៖ រយៈពេលនៃការព្យួរកិច្ចសន្យាការងារ៖**

ការព្យួរកិច្ចសន្យាការងារ ចាប់ពីថ្ងៃទី ២៤ ខែ មិនា ឆ្នាំ២០២១ ដល់ថ្ងៃទី៣១ ខែមិនា ឆ្នាំ២០២១ មូលហេតុដោយសារក្រុមហ៊ុនបានទទួលរងនូវផលប៉ះពាល់យ៉ាងអវិជ្ជមានលើផ្នែកហិរញ្ញវត្ថុ បង្កដោយវីរុស កូវីដ១៩។

**មាត្រា២៖ ប្រាក់ឧបត្ថម្ភកំឡុងពេលព្យួរកិច្ចសន្យាការងារ៖**

ភាគីនិយោជក មិនមានផ្តល់ជាប្រាក់ឧបត្ថម្ភអ្វីឡើយ កំឡុងពេលព្យួរកិច្ចសន្យាការងារនេះ។

ភាគីនិយោជិក មិនទាមទារប្រាក់ឧបត្ថម្ភអ្វីឡើយ ពីនិយោជក កំឡុងពេលព្យួរកិច្ចសន្យាការងារនេះ។ សរុបនិយោជិកទាំងអស់មានចំនួន ១១៨ ស្រី ៥៥ (និយោជិកត្រូវព្យួកិច្ចសន្យាការងារមាន ៤៣ នាក់ ស្រី ២២នាក់)។

**មាត្រា៣៖ កាលបរិច្ឆេទចូលបម្រើការងារវិញ**

បុគ្គលិកនិយោជិកទាំងអស់ត្រូវត្រឡប់ចូលមកបម្រើការងារវិញ បន្ទាប់ពីរយៈពេលព្យួរកិច្ចសន្យាការងារនេះ ត្រូវបានបញ្ចប់។

កិច្ចសន្យានេះត្រូវបានធ្វើឡើងជាពីរ(០២)ច្បាប់ និងមានតម្លៃស្មើគ្នាចំពោះមុខច្បាប់ ដែលសម្រាប់ភាគីនីមួយៗទុកម្នាក់មួយ(០១)ច្បាប់។

ភាគីទាំងបីបានអាន ព្រមព្រៀងគ្នា និងបានផ្តិតមេដៃ ដើម្បីជាសាក្ខីភាព៕

| | |
|---|---|
| **តំណាងភាគីនិយោជក** | **តំណាងភាគីនិយោជិក** |
| **លោកស្រី ជឹម សុខនី** | **លោក ឡឿន ចក្រវ៉ា** |

ព្រះរាជាណាចក្រកម្ពុជា ក្រុមហ៊ុន វើលដ៍ ដាយនីង លីមីធីត World Dining Limited KINGDOM OF CAMBODIA